ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៧៨៤ សកបយ.

ភ្នំពេញ. ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស

## ស្តីពី

## សេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ចស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ម្រេ ច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលបើកសហគ្រាស គ្រឹះស្ថាន ជាស្ថាពរ ។

**ប្រការ២.-** សំណុំលិខិត នៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានមានដូចតទៅ :-

១-សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានយកតាមគំរូក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះដោយមានបិទតែមប្រើ ១.៥០០រៀល ( មួយពាន់ប្រាំរយរៀល ) ចំនួនពីរច្បាប់ ។

២-សេចក្តីប្រកាសជូនដំណឹងស្តីអំពីបុគ្គលិកយកតាមគំរូក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ចំនួនបីច្បាប់ ។

ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងរាជធានីភ្នំពេញត្រូវបញ្ជូនសំណុំលិខិតនៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានខាងលើ ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំណែកសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត-ក្រុងផ្សេងទៀត ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។

**ប្រការ៣.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចង្អុលបង្ហាញក្នុងប្រការ១ ខាងលើ ត្រូវជូនដំណឹងមកនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងនៃមូលដ្ឋានខ្លួន នូវគ្រប់សកម្មភាពផ្លាស់ប្តូរទីតាំង ការកែប្រែរចនាសម្ព័ន្ធផលិតកម្ម ការផ្លាស់ប្តូរម្ចាស់ និងការបិទ ឬបញ្ឈប់សកម្មភាពសហគ្រាសយ៉ាងយូរបំផុត៣០ ថ្ងៃ ( សាមសិបថ្ងៃ ) បន្ទាប់ពីថ្ងៃមានការផ្លាស់ប្តូរ ឬបន្ទាប់ពីថ្ងៃដែលបញ្ឈប់សកម្មភាពសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនិងបទបញ្ញត្តិ នៃប្រកាសនេះត្រូវទទួលការពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ១៤៧ សកអ.ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
" ដើម្បីជូនជ្រាប "
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
" ដើម្បីជ្រាប "
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

ឧបសម្ព័ន្ធទី៦

ប្រកាសលេខ ...............

ថ្ងៃទី ......ខែ ........ឆ្នាំ ..........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស

១. យីហោនៃសហគ្រាស.......................................................................................

២. កាលបរិច្ឆេទនៃការបើក , ថ្ងៃទី..................ខែ........................ឆ្នាំ ......

៣. អាសយដ្ឋាននៃទីស្នាក់ការសហគ្រាស លេខ ...................... ផ្លូវ........................ សង្កាត់........................
ខណ្ឌ.............................. ក្រុង ........................... លេខទូរស័ព្ទ............................ លេខទូរសារ...............
- នាមម្ចាស់សហគ្រាស ....................................................................................... សញ្ជាតិ........................
- នាមនាយកសហគ្រាស ..................................................................................... សញ្ជាតិ........................

៤. លក្ខន្តិកៈគតិយុត្តិរបស់សហគ្រាស (១) ...............................................................................

៥. ប្រភេទសហគ្រាស (២) ...............................................................................................

៦. ទីតាំងនៃសហគ្រាស លេខ ..................... ផ្លូវ....... ................ សង្កាត់...... ............. ខណ្ឌ..................
ក្រុង ......................... លេខទូរស័ព្ទ.............................. លេខទូរសារ...........................................

៧. ចំនួននិយោជិត កម្មករ សរុប ........................នាក់ ស្រី ............... នាក់ ប្រុស .................... នាក់
ក្នុងនោះ :
- មានកម្មករ និយោជិត អាយុពី ១៥ ឆ្នាំនៅក្រោម ១៨ ឆ្នាំ ចំនួន ...................... នាក់
ស្រី ................. នាក់ ប្រុស .................. នាក់
- មានជនបរទេស ចំនួន ............... នាក់ ស្រី ................... នាក់ ប្រុស ...................... នាក់

៨. រយៈពេលនិងប្រភេទការងារពេលយប់សម្រាប់ស្ត្រី ឬ ក្មេងប្រុសនារីមានបដិបញ្ញត្តិ ..............................
.........................................................................................................................
.........................................................................................................................
.........................................................................................................................

៩. មានកម្មករ និយោជិតអាយុក្រោម ១៨ ឆ្នាំ ស្នាក់នៅក្នុងសហគ្រាសចំនួន........នាក់ (ស្រី.........នាក់)

១០. ប្រភេទនៃគ្រឿងចក្រ និងវិធីប្រើសំភារៈ វត្ថុធាតុដើមប្រកបដោយគ្រោះថ្នាក់ ..........................................................
..................................................................................................................................................
..................................................................................................................................................
..................................................................................................................................................
..................................................................................................................................................

១១. ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ..................................................................................................................

ភ្នំពេញ,ថ្ងៃទី..............ខែ...................ឆ្នាំ ....

ហត្ថលេខា ម្ចាស់ ឬ នាយកសហគ្រាស

<u>កំណត់សំគាល់ :</u>

១): សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាក្រុមហ៊ុនអនាមិក

-ឬ ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិតសីមា

-ឬ ជាក្រុមហ៊ុននៃមូលធន

-ឬ ជាសហគ្រាសឯកជន

២): សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាសហគ្រាសឧស្សាហកម្ម

-ឬ ជាសហគ្រាសសំណង់

-ឬ ជាសហគ្រាសពាណិជ្ជកម្ម

-ឬ ជាសហគ្រាសសេវាកម្ម

-ឬ ជាសហគ្រាសសិប្បកម្ម

-ឬ ជាសហគ្រាសកសិកម្ម

លិខិតប្រកាសលេខ ...២៥៥...
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១...

# សេចក្ដីប្រកាសជូនដំណឹងស្ដីពីបុគ្គលិក

| | | |
|---|---|---|
| យីហោ:............ | ផ្នែកសកម្មភាពសេដ្ឋកិច្ច:............ | ចំនួនបុគ្គលិកសព្វថ្ងៃ:............នាក់ |
| អាសយដ្ឋាន:ផ្ទះលេខ:......ផ្លូវ:......សង្កាត់:...... | ផលិតផលសំខាន់:............ | ចំនួនបុគ្គលិកមធ្យម: (១) ............នាក់ |
| ខ័ណ្ឌ:......ក្រុង:......ទូរស័ព្ទ:...... | លក្ខន្តិកៈគតិយុត្តនៃសហគ្រាស:............ | គិតត្រឹមថ្ងៃទី......ខែ......ឆ្នាំ |
| ឈ្មោះម្ចាស់គ្រឹះស្ថាន:............សញ្ជាតិ:...... | | |
| ឈ្មោះនាយកគ្រឹះស្ថាន:............សញ្ជាតិ:...... | | |

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | លេខសៀវភៅការងារ | ប្រាក់ប្រចាំខែ | របៀបបើកប្រាក់ | ថ្ងៃខែឆ្នាំចូលធ្វើការ | មុខងារ | កំរិតវប្បធម៌ ឬ កំរិតវិជ្ជាជីវៈ | ចំនួនម៉ោងធ្វើការក្នុងមួយអាទិត្យ | កំណត់សំគាល់របស់ការិយាល័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| | ក_អ្នកដឹកនាំ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ខ_និយោជិតការិយាល័យ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | គ_កម្មករជំនាញខ្ពស់ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឃ_កម្មករជំនាញ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ង_កម្មករពាក់កណ្ដាលជំនាញ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ច_កម្មករឯកទេស | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឆ_កម្មករ | | | | | | | | | | | | |
| | | | | | | | | | | | | | |

ភ្នំពេញ.ថ្ងៃទី............ខែ............ឆ្នាំ............

ហត្ថលេខាម្ចាស់ ឬនាយកសហគ្រាស

កំណត់សំគាល់ : • បើគ្មានពត៌មានដែលត្រូវចុះ ត្រូវដាក់ក្នុងខ្ទង់ទី១ ថាគ្មាន